កិច្ចសន្ទនាភាពជាដៃគូអភិវឌ្ឍន៍កាបូនតិចលើកទីបី នៅអាស៊ីបូព៌ា
ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ នៅទីក្រុង យ៉ូកូហាម៉ា ប្រទេសជប៉ុន

# សុន្ទរកថារបស់ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការ
# ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង
# ក្រសួងបរិស្ថាន ព្រះរាជាណាចក្រកម្ពុជា

- សូមគោរព ឯកឧត្តម មីណូរូ គីអូជី រដ្ឋមន្ត្រីកិច្ចការបរទេសប្រទេសជប៉ុន
- ប្រតិភូភ្ញៀវកិត្តិយសជាទីមេត្រី
- ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយ ដែលបានចូលរួមក្នុងកិច្ចសន្ទនាដ៏មានសារៈសំខាន់នេះ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តមរដ្ឋមន្ត្រី សាយ សំអាល់ ខ្ញុំសូមសំដែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលជប៉ុនដែលបានអញ្ជើញរូបខ្ញុំ និងរៀបចំកិច្ចសន្ទនាថ្នាក់តំបន់ ដ៏មានសារៈសំខាន់នេះ ហើយខ្ញុំសូមជូនពរដល់ឯកឧត្តម លោក លោកស្រីទាំងអស់ បានទទួលជោគជ័យក្នុងកិច្ចពិភាក្សានេះ ។

យើងទាំងអស់គ្នាដឹងហើយថា ការប្រែប្រួលអាកាសធាតុកើតមានពិតប្រាកដ និងត្រូវការឱ្យមានចំណាត់ការជាបន្ទាន់ ប្រកបដោយខ្លឹមសារ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំទៅនឹងផលប៉ះពាល់របស់វា។ ក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) កម្ពុជាងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ទោះបីខ្លួនបានរួមចំណែកត្រឹមតិចតួចទៅក្នុងបញ្ហានេះក៏ដោយ។ ក្នុងន័យនេះ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍ យើងផ្តោតការយកចិត្តទុកដាក់ខ្លាំងបំផុតចំពោះការប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រដល់ការកសាងសង្គមមួយបៃតង ដែលបញ្ចេញកាបូនតិច និងដែលមានភាពធន់។ ស្របពេលដែលការងារបន្សាំមានសារៈសំខាន់ជាទីបំផុតសម្រាប់យើង យើងមើលឃើញការកាត់បន្ថយការបញ្ចេញឧស្ម័នជាឱកាសមួយដើម្បីក្រសោបយកបច្ចេកវិទ្យា ដែលមានមេត្រីភាពកាន់តែច្រើនជាមួយអាកាសធាតុ ហើយផ្តល់នូវសហប្រយោជន៍ជាច្រើន បន្ថែមលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ នៅក្នុងបរិបទនេះ ខ្ញុំសូមចែករំលែកបទពិសោធន៍ខ្លះៗរបស់យើង នៅក្នុងកិច្ចសហការរវាងរដ្ឋាភិបាល និងវិស័យឯកជន និងការផ្ទេរបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិច ជាពិសេសនៅក្នុងបរិបទនៃការអនុវត្តគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ។

**ឯកឧត្តម លោក លោកស្រីជាទីមេត្រី!**

ក្នុងឋានៈជាភាគីប្រទេសអភិវឌ្ឍន៍តិចតួចមួយ នៅក្រោមពិធីសារក្យូតូ កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តគម្រោង CDM។ មកទល់បច្ចុប្បន្ននេះ គម្រោង CDM ចំនួន១០ ត្រូវបានចុះ

បញ្ជីដោយក្រុមប្រឹក្សាប្រតិបត្តិនៃ CDM ដែលគម្រោងទាំងនេះមានសក្តានុពលក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នសរុបច្រើនជាង២លានតោនសមមូលឧស្ម័នកាបូនិក ក្នុងមួយឆ្នាំៗ។ កត្តាគន្លឹះដែលរួមចំណែកក្នុងជោគជ័យនេះ រួមមាន ៖ ការប្តេជ្ញារឹងមាំរបស់រាជរដ្ឋាភិបាលចំពោះ CDM, កិច្ចសហប្រតិបត្តិការរឹងមាំក្នុងចំណោមស្ថាប័នពាក់ព័ន្ធ គោលការណ៍និងនីតិវិធីច្បាស់លាស់ ការគាំទ្របច្ចេកទេស និងការផ្តល់យោបល់ណែនាំដល់អ្នកអភិវឌ្ឍន៍គម្រោង លក្ខណៈវិនិច្ឆ័យងាយៗប៉ុន្តែពេញលេញសម្រាប់ការវាយតម្លៃគម្រោង យុទ្ធនាការខ្លាំងក្លាដើម្បីបង្កើនការយល់ដឹង ភាពម្ចាស់ការពេញលេញលើឥណទានកាបូនរបស់អ្នកអភិវឌ្ឍន៍គម្រោង និងការគាំទ្រព្រមទាំងកិច្ចសហប្រតិបត្តិការប្រកបដោយការស្ថាបនាជាមួយដៃគូនានា។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះថ្លែងអំណរគុណផងដែរចំពោះអង្គការដៃគូជប៉ុននានា ជាពិសេសវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោកនៃប្រទេសជប៉ុន (IGES) ដែលបានផ្តល់កិច្ចសហប្រតិបត្តិការប្រកបដោយការស្ថាបនា និងការគាំទ្រអស់រយៈពេលជិត ១០ឆ្នាំមកនេះ។

ក្នុងឋានៈជាយន្តការដែលផ្អែកលើទីផ្សារ CDM មានសក្តានុពលក្នុងការបញ្ចូលការវិនិយោគឯកជនទៅក្នុងសកម្មភាពអភិវឌ្ឍន៍ ដែលផ្តល់អត្ថប្រយោជន៍ខាងសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ក៏ប៉ុន្តែ ជារួមការវិនិយោគឯកជននានាតែងផ្តោតតែលើសកម្មភាពណាដែលផ្តល់ផលចំណេញខ្ពស់ ហើយដែលមានហានិភ័យខាងសេដ្ឋកិច្ចនិងនយោបាយកម្រិតទាប ពោលគឺមានន័យថានៅក្រៅបណ្តាប្រទេស LDCs។ លើសពីនេះ កម្ពុជាប្រឈមនឹងឧបសគ្គដទៃទៀតខាងបច្ចេកទេស ស្ថាប័ន និងហិរញ្ញវត្ថុ។ ឧបសគ្គទាំងនោះ មានជាអាទិ៍ សក្តានុពលទាបក្នុងការកាត់បន្ថយ ដោយសារតែសកម្មភាពឧស្សាហកម្មនានាជាពិសេសឧស្សាហកម្មថាមពលមានកម្រិតកំណត់ គម្រោងភាគច្រើនតូចៗដាច់ពីគ្នា ព័ត៌មានមានកម្រិតកំណត់ ការយល់ដឹងដែលមានកម្រិតទាប (ខាងបច្ចេកវិទ្យា ជម្រើសនៃការផ្តល់មូលនិធិ។ល។) ទិន្នន័យគោលមានកម្រិតកំណត់និងពុំសូវជាក់លាក់ សមត្ថភាពមន្ត្រីជំនាញមានកម្រិតសម្រាប់រៀបចំ វាយតម្លៃ និងអនុវត្តគម្រោង គោលការណ៍ CDM និងដំណើរការចុះបញ្ជីមានលក្ខណៈស្មុគស្មាញ តម្រូវការដើមទុនខ្ពស់សម្រាប់ការវិនិយោគនិងថ្លៃចំណាយប្រតិបត្តិការដទៃទៀតមានកម្រិតខ្ពស់ ប្រព័ន្ធធនាគារនៅក្នុងពុំទាន់អភិវឌ្ឍន៍បានពេញលេញ (អត្រាការប្រាក់ខ្ពស់ គ្មានអំឡុងពេលអនុគ្រោះ ការផ្តល់កម្ចីសម្រាប់រយៈពេលខ្លី លក្ខខណ្ឌតឹងរ៉ឹងតម្រូវឱ្យមានដាក់វត្ថុបញ្ចាំ កម្ចីមានសម្រាប់តែបច្ចេកវិទ្យានិងសកម្មភាពតាមប្រពៃណី) និងភាពមិនប្រាកដប្រជានៃថ្លៃកាបូន។

ក្រៅពី CDM កម្ពុជាក៏បានធ្វើការប្រឹងប្រែងយ៉ាងច្រើនផងដែរដើម្បីអនុវត្តគម្រោងកាត់បន្ថយតាមរយៈយន្តការផ្សេងៗទៀត ដូចជារ៉េដបូក (REDD+) ទីផ្សារកាបូនស្ម័គ្រចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ក៏ជោគជ័យនៅមានកម្រិត ដោយសារការប្រឈមប្រហែលគ្នានេះ ដូចដែលបានបង្ហាញពីខាងដើម។ ថ្មីៗនេះ ក្រោមកិច្ចសហប្រតិបត្តិការជាមួយជប៉ុន យើងក៏បានចាប់ផ្តើមការងាររៀបចំសម្រាប់គាំទ្រដល់ការអនុវត្តយន្តការឥណទានរួមគ្នា (JCM) ផងដែរ ហើយគម្រោង JCM ដែលមានសក្តានុពលមួយចំនួន ត្រូវបានកំណត់រួចមកហើយនៅក្នុងគ្រោងការរបស់យើង។

ទាក់ទងនឹងការផ្ទេរបច្ចេកវិទ្យា យើងជឿថា យន្តការទីផ្សារដែលមាន នៅពុំទាន់គ្រប់គ្រាន់សម្រាប់ជម្រុញការផ្ទេរបច្ចេកវិទ្យា ដោយសារយន្តការទាំងនោះផ្តោតតែលើផលចំណេញ និងអវត្តមាននៃយន្តការដែលតម្រូវឱ្យដាក់បញ្ចូលការខូចខាតដល់អាកាសធាតុពិភពលោក។ លើសពីនេះ តាមធម្មតាបច្ចេកវិទ្យាថ្មីៗដែលមានមេត្រីភាពជាមួយអាកាសធាតុ តែងមានតម្លៃខ្ពស់ (ដោយសារតែបញ្ហាកម្មសិទ្ធិបញ្ញា) ដែលជាឧបសគ្គចំពោះវិស័យឯកជន។ ក្នុងន័យនេះ គោលការណ៍ "ការផ្គត់ផ្គង់ និងតម្រូវការ" តែឯង មិនអាចគ្រប់គ្រាន់ឡើយក្នុងការជម្រុញការផ្ទេរបច្ចេកវិទ្យា។ ដូច្នេះ បង្គុំនៃយន្តការផ្អែកផ្លូវច្បាប់និងទីផ្សារ គួរត្រូវយកមកប្រើប្រាស់ ដើម្បីលើកកំពស់ការផ្ទេរបច្ចេកវិទ្យា។ ដោយឡែកសម្រាប់ LDCs ការផ្ទេរបច្ចេកវិទ្យាគួរតែមានលក្ខណៈទូលាយ និងពាក់ព័ន្ធយ៉ាងហោចណាស់ជាមួយការផ្តល់សម្ភារៈបរិក្ខារ ជំនាញ ព័ត៌មានដែលពាក់ព័ន្ធ ការកសាងសមត្ថភាពមនុស្ស និងធនធានហិរញ្ញវត្ថុ។ ក្នុងកាលៈទេសៈខ្លះ ការផ្ទេរបច្ចេកវិទ្យាត្បូង-ត្បូងក៏អាចមានលក្ខណៈសមស្របផងដែរ។

ឯកឧត្តម លោក លោកស្រីជាទីមេត្រី!

គោលគំនិតអំពីការអភិវឌ្ឍដែលបញ្ចេញកាបូនតិចផ្តល់ភាពទាក់ទាញ សម្រាប់ប្រទេសនានាដូចកម្ពុជា ដែលបានឆ្លងកាត់ការអភិវឌ្ឍសេដ្ឋកិច្ចឆាប់រហ័ស នាំឱ្យមានតម្រូវការថាមពលកាន់តែច្រើនឡើង។ ជាការច្បាស់ណាស់ថា កម្ពុជាអាចទទួលផលពីការអភិវឌ្ឍដែលបញ្ចេញកាបូនតិច ដោយកាត់បន្ថយការពឹងផ្អែកលើឥន្ធនៈហ្វូស៊ីលដែលនាំចូល កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទទួលបានបច្ចេកវិទ្យាដែលមានមេត្រីភាពនឹងបរិស្ថាន បង្កើតការងារកាន់តែច្រើនឡើង លើកកំពស់ជីវភាពរស់នៅ និងទ្រទ្រង់ដល់ការអភិវឌ្ឍដោយចីរភាព។ ក្នុងពេលដែលយើងត្រូវការឱ្យមានកិច្ចប្រឹងប្រែងផ្ទាល់ខ្លួនច្រើនថែមទៀត ដើម្បីដោះស្រាយការប្រឈមនានា ដែលបានពោលខាងលើ ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេស LDCs ត្រូវការនូវការគាំទ្រថែមទៀតពីខាងក្រៅ ដើម្បីអាចប្រើប្រាស់ពេញលេញនូវសក្តានុពលដែលបានពីការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។ គោលនយោបាយដែលមានស្រាប់ និងឧបសគ្គខាងស្ថាប័នអាចនឹងជំនះបាន តាមរយៈការប្តេជ្ញារបស់រដ្ឋាភិបាល និងការចូលរួមយ៉ាងសកម្មពីសំណាក់វិស័យឯកជន និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ ការប្តេជ្ញារបស់អ្នកពាក់ព័ន្ធ ត្រូវតែធ្វើឡើងស្របគ្នាជាមួយការគាំទ្របន្ថែមទៀតពីម្ចាស់ជំនួយ និងភាពជាដៃគូកាន់តែរឹងមាំរវាងវិស័យសាធារណៈនិងឯកជន ទើបយើងអាចទទួលជោគជ័យក្នុងការឈានតាមលំនាំនៃការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។ ខ្ញុំជឿជាក់ថា ការលេចឡើងនៃកិច្ចផ្តួចផ្តើមថ្មីៗ ដូចជា យន្តការឥណទានរួមគ្នា នឹងរួមចំណែកក្នុងការសម្រេចគោលដៅនេះ។ ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។